# ព្រឹត្តិបត្រប្រចាំត្រីមាសទី១

**ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប**

ខែមករា ដល់ ខែមីនា ឆ្នាំ២០២៥

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ **ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)** និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខ: ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ត្រីមាសទី១ ឆ្នាំ២០២៥ សមាគមមានសមាជិកសរុបចំនួន ៣៣៤ស្ថានីយ/ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣ រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៨០ស្ថានីយ និងសមាជិកគាំទ្រចំនួន ៥៤ក្រុមហ៊ុន។។

## ២. ការខារស្នូលសមាគម

### ២.១ ផែនការយុទ្ធសាស្រ្ត ៥ឆ្នាំ (២០២៥ - ២០៣០)

តាមរយៈកម្មវិធី CAPRED ប្រទេសអូស្ត្រាលីបានគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងសមាគមទឹកអូស្ត្រាលី (AWA) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ក្នុងការរៀបចំផែនការយុទ្ធសាស្រ្តសម្រាប់ឆ្នាំ២០២៥-២០៣០របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ ក្នុងនោះដៃរទីប្រឹក្សាអភិវឌ្ឍន៍ផែនការយុទ្ធសាស្រ្តរបស់កម្មវិធី CAPRED បានប្រើប្រាស់វិធីសាស្រ្តចម្រុះរួមមាន៖ សម្ភាស ពិភាក្សាក្រុម ប្រជុំ និងសិក្ខាសាលា ដើម្បីប្រមូលព័ត៌មាន ពីសមាជិកអាជីព សមាជិកគាំទ្រ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម អង្គការដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧត្តុនិយម។ ព័ត៌មានប្រមូលបានទាំងអស់ត្រូវបានយកមកវិភាគ និងពិភាក្សាជាមួយអ្នកជំនាញផ្នែកសរសេរផែនការយុទ្ធសាស្រ្តរបស់សមាគមទឹកអូស្ត្រាលី ដើម្បីរៀបចំជា

ផែនការយុទ្ធសាស្ត្រ និងសុំការសម្រេចពី ក្រុមប្រឹក្សាភិបាលសមាគម។ ជាលទ្ធផល ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៥-២០៣០ របស់សមាគម រួមមាន៖

១. ពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងនិរន្តរភាពសមាជិក ដើម្បីផ្តល់សេវាទឹកស្អាតប្រកបដោយការទទួលខុសត្រូវ រួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
២. បង្កើនគុណភាពនៃការចូលរួមរបស់សមាជិក និងសេវាកម្មផ្តោតលើគុណតម្លៃរបស់សមាជិក
៣. លើកកម្ពស់ភាពជាតំណាងសមាជិកប្រកបដោយប្រសិទ្ធភាព និងតស៊ូមតិដោយផ្អែកលើភស្តុតាងសម្រាប់សមាជិក និងនិរន្តរភាពនៃវិស័យ។
៤. ពង្រឹងសមត្ថភាពស្ថាប័ន និងនិរន្តរភាពហិរញ្ញវត្ថុសមាគមដើម្បីផ្តល់សេវាកម្មតាមប្រកបដោយប្រសិទ្ធភាព។




*រូបភាពទី១៖ រូបតំណាង ផែនការយុទ្ធសាស្ត្រសមាគម ២០២៥ - ២០៣០*

*តារាងទី១៖ អាទិភាពយុទ្ធសាស្ត្រគន្លឹះ*

| គោលបំណងរបស់យុទ្ធសាស្ត្រ | អាទិភាពយុទ្ធសាស្ត្រគន្លឹះ | |
|---|---|---|
| **គោលបំណងយុទ្ធសាស្ត្រទី១**<br>ពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងនិរន្តរភាពរបស់សមាជិក ដើម្បីផ្តល់សេវាទឹកស្អាតប្រកបដោយការទទួលខុសត្រូវ រួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ | ១.១ | បង្កើនប្រសិទ្ធភាពនៃការសម្របសម្រួលសមាជិកភាព ចំណេះដឹងលើវិស័យ និងការគ្រប់គ្រងព័ត៌មានប្រកបដោយភាពច្នៃប្រឌិតសម្រាប់វិស័យទឹកស្អាត។ |
| | ១.២ | រៀបចំយុទ្ធសាស្ត្រផែនទីបង្ហាញផ្លូវ និងកម្មវិធីពង្រឹងសមត្ថភាពសមាជិកក្នុងការផ្តល់ និងពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយទំនួលខុសត្រូវក្នុងការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ឆ្នាំ២០៣០ |

| គោលបំណងរបស់យុទ្ធសាស្ត្រ | អាទិភាពយុទ្ធសាស្ត្រគន្លឹះ |
|---|---|
| | ១.៣ ពង្រឹងការអនុវត្តប្រកបដោយទំនួលខុសត្រូវ ដើម្បីបង្កើនភាពធន់ និងនិរន្តរភាពរបស់សមាជិក និងវិស័យ។ |
| **គោលបំណងយុទ្ធសាស្ត្រទី២**<br>បង្កើនគុណភាពនៃការចូលរួមរបស់សមាជិក និងសេវាកម្មផ្តោតលើគុណតម្លៃរបស់សមាជិក | ២.១ ពង្រឹង និងបង្កើតបណ្តាញសម្រាប់ការចូលរួមរបស់សមាជិក |
| | ២.២ ផ្តល់ជូនសេវាកម្មឱ្យត្រូវនឹងតម្រូវការចម្រុះ |
| | ២.៣ លើកកម្ពស់ការចូលរួមរបស់សមាជិក និងចូលរួមសហការដោះស្រាយប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍន៍សម្រាប់សមាជិក និងវិស័យ។ |
| **គោលបំណងយុទ្ធសាស្ត្រទី៣**<br>លើកកម្ពស់ភាពជាតំណាងសមាជិកប្រកបដោយប្រសិទ្ធភាព និងតស៊ូមតិដោយផ្អែកលើភស្តុតាងសម្រាប់សមាជិក និងនិរន្តរភាពនៃវិស័យ។ | ៣.១ ពង្រឹងការសម្របសម្រួលជាយុទ្ធសាស្ត្រ និងភាពជាដៃគូប្រកបដោយទំនុកចិត្តជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ |
| | ៣.២ កែលម្អគុណភាពនៃការកំណត់អាទិភាពនៃបញ្ហាដែលទាក់ទងនឹងសមាជិក |
| | ៣.៣ ពង្រឹងកិច្ចសន្ទនា និងការតស៊ូមតិដោយផ្អែកលើភស្តុតាងសម្រាប់សមាជិក និងវិស័យអាទិភាព នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ |
| **គោលបំណងយុទ្ធសាស្ត្រទី៤**<br>ពង្រឹងសមត្ថភាពស្ថាប័ន និងនិរន្តរភាពហិរញ្ញវត្ថុរបស់ CWA ដើម្បីផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិក និងជាតំណាងសមាជិកប្រកបដោយប្រសិទ្ធភាពសម្រាប់វិស័យនេះ។ | ៤.១ ពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ស្ថាប័ន ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពនៃសមាគម |
| | ៤.២ ពង្រឹងផែនការកៀងគរធនធាន ប្រកបដោយនិរន្តរភាព |
| | ៤.៣ លើកកម្ពស់ការអនុវត្តការត្រួតពិនិត្យ និងវាយតម្លៃ ដែលផ្តោតទៅលើលទ្ធផល និងវប្បធម៌នៃការរៀនសូត្រ។ |

ផ្នែកមួយនៃយុទ្ធសាស្ត្រគន្លឹះគឺការបង្កើត **«មូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត(ម.អ.ស.វ.)»** របស់សមាគមដែលនឹងដាក់ឱ្យដំណើរការនៅថ្ងៃប្រារព្ធសន្និបាតលើកទី១៣ នេះជាផែនការយុទ្ធសាស្ត្រសមាគមមួយសម្រាប់ឆ្នាំ២០២៥-២០៣០។ មូលនិធិនេះបង្កើតឡើងក្នុងគោលបំណងជាក់លាក់ដូចខាងក្រោម៖

១. ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃទឹកស្អាតសម្រាប់សុខភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។
២. កែលម្អការយល់ដឹងជាវិជ្ជមានអំពីតួនាទីសំខាន់ៗរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (PWO) ក្នុងការពង្រីកលទ្ធភាពទទួលបានទឹកស្អាត។
៣. គាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ក្នុងការដោះស្រាយបញ្ហាដែលប៉ះពាល់ ដល់ផលប្រយោជន៍រួមរបស់ពួកគេ ដើម្បីធានាបាននូវវិស័យផ្គត់ផ្គង់ទឹកស្អាតប្រកបដោយភាពធន់ និងនិរន្តរភាព។
៤. លើកកម្ពស់ភាពជាវិជ្ជមានសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត ដើម្បីកសាងទំនុកចិត្តក្នុងចំណោម សហគមន៍ អ្នកពាក់ព័ន្ធ និងរាជរដ្ឋាភិបាល។
៥. ផ្តួចផ្តើមគម្រោង ឬសកម្មភាពដែលផ្តល់ផលប្រយោជន៍ដល់ប្រយោជន៍រួមរបស់សមាជិក និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃវិស័យទឹកស្អាតនៅកម្ពុជា។

តាមរយៈនៃការអនុវត្តតាមផែនការយុទ្ធសាស្ត្រនេះ សមាគមអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជួយសមាជិកក្នុងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ដើម្បីផ្តល់សេវាទឹកស្អាតប្រកបដោយ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ដើម្បីរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។




*រូបភាពទី២៖ ការធ្វើបទបង្ហាញដោយលោកស្រី Fiona (សមាគមទឹកអូស្ត្រាលី)*



*រូបភាពទី៣៖ កិច្ចប្រជុំជាសមាគមទឹកអូស្ត្រាលី*

## ២.២ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាសមាគមប្រចាំត្រីមាសទី៤ សម្រាប់ឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២។ កិច្ចប្រជុំនេះដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានសមាគម ព្រមទាំងមាន

ការអញ្ជើញចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម សរុបចំនួន ១៣នាក់ (ស្រី ៥នាក់)។ កិច្ចប្រជុំមានរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

១. លទ្ធផលការងារសមាគមត្រីមាសទី៤ ឆ្នាំ២០២៤ និងផែនការសកម្មភាពត្រីមាសទី១ ឆ្នាំ២០២៥
២. ការរៀបចំសន្និបាតលើកទី១៣ ប្រចាំឆ្នាំ២០២៤
៣. វិសោធនកម្មគោលនយោបាយហិរញ្ញវត្ថុ (៤.២ មូលដ្ឋានគណនេយ្យ)
៤. ការដាក់ឱ្យដំណើរការមូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាតរបស់សមាគម។



*រូបភាពទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រីមាសទី៤ សម្រាប់ឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២*

## ២.២ សន្និបាតសមាគមលើកទី១៣

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥ សមាគម បានរៀបចំសន្និបាតលើកទី ១៣ សម្រាប់ឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ ក្នុងគោលបំណង៖

១. អបអរសាទរសមិទ្ធផលរបស់សមាគមក្នុងឆ្នាំ២០២៤ និងរៀបចំផែនការការងារប្រចាំឆ្នាំ២០២៥
២. ដាក់ដំណើរការ«ផែនការយុទ្ធសាស្ត្រសមាគមសម្រាប់ឆ្នាំ២០២៥-២០៣០»និង «មូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត (ម.អ.ស.វ.) របស់សមាគម CWA»
៣. បង្កើនទំនាក់ទំនងរវាងសមាជិកសមាគម ឱ្យកាន់តែប្រសើរឡើង និងចែករំលែកបច្ចេកវិទ្យាថ្មីៗ។

អង្គសន្និបាតប្រារព្ធទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ **លោកស្រី Kirsty Harris** ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៃស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង **លោក ឡេង ខៀវ** ប្រធានសមាគម។ អង្គសន្និបាតមានអ្នកចូលរួមសរុបចំនួន ៤០៥នាក់ ស្រី១១៥នាក់ ដែលអញ្ជើញមកពី ក្រសួងឧ.វ.ប.ន. ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជន ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា កម្មវិធី CAPRED អង្គការ Water.org សមាជិកអាជីព និងសមាជិកគាំទ្រ អង្គការដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ WaterAid, EMW, AEA, WB, ADB, JICA, KOWBA ព្រមទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។

អង្គសន្និបាតទទួលបានការឧបត្ថម្ភពី កម្មវិធី CAPRED អង្គការ Water.org និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន ព្រមទាំងទទួលបានកិច្ចសហការឧបត្ថម្ភពី៖ ១). ក្រុមហ៊ុនដៃគូទឹកកម្ពុជា ២). ក្រុមហ៊ុន កូមិនខ្មែរ ចំកាត់ ៣). ក្រុមហ៊ុន K&K Pipe ៤). ក្រុមហ៊ុន KCRI International Cooperation Co., Ltd. ៥). ក្រុមហ៊ុន TCU (Cambodia) Co., Ltd. ៦). ក្រុមហ៊ុន MOLECOR South East Asia ៧). Phnom Penh Plastic Product Co., Ltd. ៨). Watermech Technology Co., Ltd. ៩). ក្រុមហ៊ុន Techzone Plus ១០). Pump Electric Solution Co., Ltd. ១១). E-Power CCL. ១២). TEM Trading Co., Ltd. ១៣). ធនាគារ FTB ១៤). AMK MFI Plc. ១៥). SME Bank។



*រូបភាពទី៥៖ ការថតរូបអនុស្សាវរីយ៍រួងជាមួយគណអធិបតី*

អង្គសន្និបាតឆ្នាំនេះផ្តោតសំខាន់ទៅលើការដាក់ឲ្យដំណើរការ ***«ផែនការយុទ្ធសាស្ត្ររបស់សមាគម ឆ្នាំ២០២៥-២០៣០» និង «មូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត (ម.អ.ស.វ.) របស់សមាគម»*** ។ ផែនកាកយុទ្ធសាស្ត្រ និងមូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត នេះនឹងរួមចំណែកក្នុងការជួយសល់សមាជិកសមាគមក្នុងការបង្កើន សមត្ថភាពវិជ្ជាជីវៈ សម្រាប់ការផ្តល់សេវាទឹកស្អាតប្រកបដោយ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ដើម្បីរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។



*រូបភាពទី៦៖ ការដាក់ឲ្យដំណើរការផែនការយុទ្ធសមាគម ២០២៥-២០២៣ និងមូនិធិអភិវឌ្ឍន៍សមាជិក និងវិស័យ*

## ២.២ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៤

ថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០២៥ សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពការងារឆ្នាំ២០២៤ និងផែនការសកម្មភាពឆ្នាំ២០២៥ នៅការិយាល័យសមាគម ដោយមានការចូលរួមពីបុគ្គលិក និងក្រុមប្រឹក្សាភិបាល។ គោលបំណងនៃកិច្ចប្រជុំ៖

- ដើម្បីឆ្លុះបញ្ចាំងការងារសមាគមឆ្នាំ២០២៤ និងរៀបចំផែនការសម្រាប់ឆ្នាំ២០២៥
- ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផល សន្និបាតសមាគមលើកទី ១៣ សម្រាប់ឆ្នាំ២០២៤ និងអនុសាសន៍សម្រាប់ការរៀបចំព្រឹត្តិការណ៍បន្តរបស់សមាគមក្នុងឆ្នាំ២០២៥
- ការរំលឹកឡើងវិញលើគោលនយោបាយសមាគម (គោលនយោបាយបុគ្គលិក គោលនយោបាយហិរញ្ញវត្ថុ គោលនយោបាយសមាជិក គោលនយោបាយយេនឌ័រ គៃបន្លំ គាំពារកុមារ ការពារការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ)
- បង្កើនទំនាក់ទំនងរវាងបុគ្គលិក និងក្រុមប្រឹក្សាភិបាល។



*រូបភាពទី៧៖ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំនៅការិយាល័យសមាគម*

ក្នុងកិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៤ នេះក៏មានរៀបចំដំណើរកម្សាន្តមួយសម្រាប់បុគ្គលិក និងក្រុមប្រឹក្សាភិបាលឆ្ពោះទៅកាន់ឆ្នេររាម ខេត្តព្រះសីហនុ ដើម្បីកសាងទំនាក់ទំនងការងារក្រុម និងសម្រាកលំហែពីការងារផងដែរ។



*រូបភាពទី៨៖ River of Life នៃការងារសមាគមសម្រាប់ឆ្នាំ២០២៤ និងការរំពឹងទុកសម្រាប់ឆ្នាំ២០២៥*

## ២.៣ ការចុះសួរសុខទុក្ខសមាជិក

ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ សមាគមបានដឹកនាំសមាជិកសមាគមទៅសួរសុខទុក្ខម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើង ដែលមានទីតាំងនៅភូមិតាកយ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ក្នុងការចុះសួរសុខទុក្ខនេះ ក្រុមការងារសមាគម បានពិភាក្សាពីបញ្ហាដែលស្ថានីយបាននឹងកំពុងជួបប្រទះ និងបានផ្តល់ជាអនុសាសន៍តាមបច្ចេកទេសជូនម្ចាស់ស្ថានីយ ដើម្បីចាត់វិធានការដោះស្រាយជាបន្ទាន់រួមមាន៖ ១).បង្កើនថាមពលអគ្គិសនីឱ្យបានគ្រប់គ្រាន់ដើម្បីធានាការបូមទឹកពីទន្លេមេគង្គមកផលិត និងចែកចាយ ២).កែលម្អអាងប្រព្រឹត្តិកម្មដើម្បីធានាបរិមាណនៃការផលិតទឹកស្អាតប្រកបដោយគុណភាព ៣).បន្ថែមបំពង់មេ(ដំឡើងមុខកាត់)នាំទឹកស្អាតដើម្បីធានានិរន្តរភាពនៃផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋបានគ្រប់គ្រាន់។



*រូបភាពទី៩៖ ការតេស្តគុណភាពទឹកប្រភព និងទឹកស្អាត*



*រូបភាពទី១០៖ ពិនិត្យអាងប្រព្រឹត្តកម្ម និងផ្តល់អនុសាសន៍*

## ២.៤ ទស្សនកិច្ចសិក្សាក្រៅប្រទេស

ថ្ងៃទី១៩-២២ ខែមីនា ឆ្នាំ២០២៥ សមាគមបានដឹកនាំសមាជិកចំនួន ១៦នាក់/ស្ថានីយ ចូលរួមសន្និសីទទឹក ប្រទេសហ្វីលីពីន ឆ្នាំ២០២៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្រោមប្រធានបទ«**នវានុវត្តន៍ បរិយាបន្នទឹកអនាគត និងនិរន្តភាពទៅនឹងភាពធននឹងអាកាសធាតុពិភពលោក**» និងការទស្សនាស្តង់ផលិតផលនានាដែលបានដាក់បង្ហាញ។




*រូបភាពទី១១៖ ការទស្សនាស្តង់ដាក់បង្ហាញផលិតផល*

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ **លោក លឹម មិញ** នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាទឹកថ្នាក់តំបន់ ស្តីពី «ភាពធន់នឹងអាកាសធាតុក្នុងការផ្គត់ផ្គង់ទឹក និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ដោយផ្តោតលើ **វឌ្ឍនភាព បញ្ហាប្រឈម និងឱកាសក្នុងការអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា**»។




*រូបភាពទី១២៖ ការធ្វើបទបង្ហាញអំពី វឌ្ឍនភាព បញ្ហាប្រឈម និងឱកាសក្នុងការអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា*

## ៣. កិច្ចសហប្រតិបត្តិការ

### ៣.១ កិច្ចសហការអន្តរជាតិ

នៅក្នុងត្រីមាសទី១ សមាគមបានជួបប្រជុំជាមួយក្រុមហ៊ុន និងដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម៖

១. ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ សមាគម បានជួបប្រជុំជាមួយ លោក Nimesh Modak មកពី ក្រុមហ៊ុន Imagine H2O Asia។ តំណាងសមាគមរួមមាន៖ លោក ឡេង ខៀវ ប្រធានសមាគម និងជាម្ចាស់ស្ថានីយ ឡេង ខៀវ ព្រែកអំបិល លោកស្រី ស៊ីម សៀមនី អនុប្រធានសមាគម និងជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ និងលោក លឹម មិញ នាយកប្រតិបត្តិសមាគម។ កិច្ចប្រជុំបានផ្តោតលើប្រធានបទសំខាន់ៗដូចខាងក្រោម៖

- ❖ ការណែនាំអំពីកម្មវិធីរបស់ Imagine H2O Asia និងអត្ថប្រយោជន៍នៅក្នុងប្រទេសកម្ពុជា។
- ❖ ស្វែងយល់អំពីតម្រូវការ និងអាទិភាពបច្ចេកវិទ្យាទឹករបស់សមាគម និងសមាជិករបស់ខ្លួន។
- ❖ ស្វែងរកឱកាសសហការដែលមានសក្តានុពលក្នុងឆ្នាំ២០២៥។

កិច្ចពិភាក្សាបានលើកឡើងលើបញ្ហាប្រឈមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា ជាពិសេសក្នុងការទទួលយកបច្ចេកវិទ្យាថ្មីៗ។ ភាគីទាំងពីរបានរិះរកវិធីក្នុងការសម្របសម្រួលកិច្ចសហការរវាង Imagine H2O Asia និង CWA ក្នុងការណែនាំយកបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតនេះមកកម្ពុជា ដើម្បីបានជាប្រយោជន៍ដល់សមាជិកសមាគម។




*រូបភាពទី១៣៖ កិច្ចប្រជុំជាមួយក្រុមហ៊ុន Imagine H2O Asia*

### ៣.២ កិច្ចសហការថ្នាក់ជាតិ

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមក្នុងពិធីអបអរសាទរទិវាទឹក និងឧតុនិយម ពិភពលោក ឆ្នាំ២០២៥ ដែលប្រារព្ធធ្វើឡើងនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម និងពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ សាស្ត្រាចារ្យ និងនិស្សិតមកពីសាកលវិទ្យាល័យនានា សរុបប្រមាណ ៤០០នាក់។




*រូបភាពទី១៤៖ កិច្ចពិភាក្សាក្នុងទិវាទឹក និងឧតុនិយម ពិភពលោក*

ពិធីអបអរសាទរទិវាទឹក និងឧតុនិយមពិភពលោក ឆ្នាំ២០២៥ ដែលរៀបចំរួមគ្នាដោយ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប។ ក្នុងនោះក៏មានកិច្ចពិភាក្សាលើប្រធានបទ **«តើកម្ពុជាគួររៀបចំខ្លួនអ្វីខ្លះដើម្បីធានាបាននូវសន្តិសុខទឹកក្នុងបរិបទដែលមានការប្រែប្រួលអាកាសធាតុ?»** ដែលមានវាគ្មិនចូលរួមមកពីក្រសួងស្ថាប័នចំនួន៦ រួមមាន៖ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងអភិវឌ្ឍន៍ជនបទ។




*រូបភាពទី១៥៖ ការទស្សនាស្តង់របស់ក្រុមហ៊ុន តែជីមិច និងសមាគម*

## ៤.    ការអភិវឌ្ឍសមាគម និងការផ្សព្វផ្សាយ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ សមាគមមានការផ្សព្វផ្សាយព័ត៌មានតាមរយៈទំព័រហ្វេសប៊ុក ដែលមានលទ្ធផលដូចខាងក្រោម៖

| ល.រ | ការបរិយាយ | ពីខែមករា - ខែមីនា ឆ្នាំ២០២៥ |
|---|---|---|
| ១ | ចំនួនដងនៃផ្សព្វផ្សាយ | ៦០ដង |
| ២ | ចំនួនអ្នកដែលបានឃើញ (Reached) | ៣៩,៧០០នាក់ |
| ៣ | ចំនួនដងនៃការចែកចាយបន្ត | ៣៤៧ដង |
| ៤ | ចំនួនសរុបនៃអ្នកចុចចូលចិត្ត (Liked Page) | ១២,៣៦៣នាក់ |
| ៥ | ចំនួនសរុបអ្នកតាមដាន (Followers) | ១៤,៣២៦នាក់ |

## ៥.    ការងារគម្រោង

### ៥.១ គម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

#### ៥.១.១ សិក្ខាសាលាតម្រង់ទិស

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ សមាគម បានរៀបចំសិក្ខាសាលាតម្រង់ទិសគម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» ក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុល បុណ្ណារិទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងឧ.វ.ប.ន. **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម និង **លោកស្រី អយ សត្យា** អ្នកដឹកនាំផលប័ត្រ អង្គការ Water.org។ សិក្ខាសាលាមានអ្នកចូលរួមសរុប ៤៣នាក់ (ស្រី ១១នាក់) ដែលអញ្ជើញមកពីក្រសួងឧ.វ.ប.ន. អង្គការ Water.org បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។



*រូបភាពទី១៦៖ រូបថតអនុស្សាវរីយ៍សិក្ខាសាលាតម្រង់ទិស*

សិក្ខាសាលាតម្រង់ទិសមានគោលបំណង៖

១). បង្ហាញអំពីទិដ្ឋភាពទូទៅនៃគម្រោង គោលបំណង និងផែនការសកម្មភាពចម្បងៗរបស់គម្រោង

២). បង្ហាញអំពីទិដ្ឋភាពទូទៅនៃប្រព័ន្ធទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតសម្រាប់ស្វែងរកទុនកម្ចីពីស្ថាប័នហិរញ្ញវត្ថុ

៣). ស្វែងរកការគាំទ្រពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការចូលរួមសកម្មភាពរបស់គម្រោង

៤). ចែករំលែកចំណេះដឹងអំពីអភិបាលកិច្ចល្អសម្រាប់សហគ្រាសធនតូច និងមធ្យម។

**៥.១.២ វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស**

ក្នុងត្រីមាសទី១ សមាគមបានសម្របសម្រួលវគ្គបណ្តុះបណ្តាលចំនួន ២លើកគឺ៖

**លើកទី១៖** ពីថ្ងៃទី១០-១៣ ខែកុម្ភៈ ឆ្នាំ២០២៥ សមាគម បានសហការជាមួយមន្ទីរ ឧ.រ.ប.ន. ខេត្តសៀមរាប រៀបចំវគ្គបណ្តុះបណ្តាល វគ្គទី២ ស្តីពី«**ការកាត់បន្ថយទឹកគ្មានចំណូល**» ក្រោមការឧបត្ថម្ភពីអង្គការ Water.org នៅសណ្ឋាគារអង្គរប៉ារាឌី ខេត្តសៀមរាប និងបានអនុវត្តមេរៀនផ្ទាល់នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម។ វគ្គបណ្តុះបណ្តាលនេះ សម្របសម្រួលដោយ លោកគ្រូជំនាញបច្ចេកទេស អញ្ជើញមកពីប្រទេសឥណ្ឌូនេស៊ី ដែលមានចំណេះដឹង ជំនាញលើការអនុវត្ត ការកាត់បន្ថយទឹកគ្មានចំណូល ជាច្រើនឆ្នាំ។ សមាសភាពអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះសរុបចំនួន ៥១នាក់ (ស្រី ៦នាក់) អញ្ជើញមកពី មន្ទីរ ឧ.រ.ប.ន. ខេត្តសៀមរាប តំណាងអង្គការ Water. org កម្ពុជា និងឥណ្ឌូនេស៊ី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសមាគម។



*រូបភាពទី១៧៖ រូបថតអនុស្សាវរីយ៍ក្នុងវគ្គបណ្តុះបណ្តាល*

សកម្មភាពសិក្ខាកាមអនុវត្តការប្រើប្រាស់ឧបករណ៍ស្វែងរកទឹកលេចធ្លាយនៅថ្ងៃទី២ ក្នុងវគ្គបណ្តុះបណ្តាលស្តីពី «**ការកាត់បន្ថយទឹកគ្មានចំណូល**» នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម។



*រូបភាពទី១៨៖ សកម្មភាពអនុវត្តឧបករណ៍ស្វែងរកទឹកបាត់បង់ក្នុងវគ្គបណ្តុះបណ្តាល*

**លើកទី**២. ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ សមាគមបានរៀបចំវគ្គបង្វឹកលើការប្រើប្រាស់ឧបករណ៍ស្វែងរកទឹកបាត់បង់ នៅស្ថានីយទឹកស្អាតសំបួរមាស។ សមាសភាពអ្នកចូលរួមមាន៖ បុគ្គលិកសមាគម បុគ្គលិកស្ថានីយទឹកស្អាតសំបួរមាស បុគ្គិលិកក្រុមហ៊ុន វ៉ធើម៉ិច ថេកណឡជី និងនិស្សិតហាត់ការ។ វគ្គបង្វឹកលើការប្រើប្រាស់ឧបករណ៍ស្វែងរកទឹកបាត់បង់ រៀបចំឡើងក្នុងគោលបំណង៖

១). ស្វែងយល់ពីរបៀបប្រើប្រាស់ឧបករណ៍ស្វែងរកទឹកបាត់បង់តាមរយៈការស្តាប់សំឡេង។
២). អនុវត្តរបៀបប្រើប្រាស់ឧបករណ៍ស្វែងរកទឹកបាត់បង់តាមរយៈការស្តាប់សំឡេងនៅទីតាំងស្ថានីយផ្ទាល់។
៣). ប្រមូលមេរៀនរៀនសូត្រពីការអនុវត្តជាក់ស្តែង ដើម្បីរៀបចំសកម្មភាពសម្រាប់ការងារបង្វឹកនៅវគ្គបន្ទាប់។




*រូបភាពទី១៩៖ សកម្មភាពពន្យល់ពីរបៀបប្រើប្រាស់ឧបករណ៍ស្វែងរកទឹកបាត់បង់*



*រូបភាពទី២០៖ សកម្មភាពអនុវត្តឧបករណ៍ស្វែងរកទឹកបាត់បង់*

### ៥.១.៣ ការកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥ សមាគមបានសម្របសម្រួលកិច្ចប្រជុំតាមអនឡាញរវាងប្រតិបត្តិករ អង្គការ Water.org និងសមាគម ដើម្បីពិភាក្សាអំពីប្រព័ន្ធគណនេយ្យ របស់ក្រុមហ៊ុនបញ្ជី(BanhJi)។ ជាលទ្ធផល ប្រតិបត្តិករបានឯកភាពក្នុងការសាកល្បងក្នុងការបដិភាគថវិកាជួលសេវាបុគ្គលិកក្រុមហ៊ុនបញ្ជី(BanhJi) ក្នុងការជួយរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញពីប្រតិបត្តិករចំនួន ២២នាក់។




*រូបភាពទី២១៖ កិច្ចប្រជុំតាមអនឡាញ*

### ៥.១.៤ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

#### *ក. ការសម្របសម្រួលកម្ចី*

គម្រោងបានសម្របសម្រួល និងតាមដានសមាជិកទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ(FIs)។ ជាលទ្ធផល ប្រតិបត្តិករចំនួន ១ស្ថានីយទទួលបានប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មចំនួន **៧២.០០០ដុល្លារអាមេរិក** ពីធនាគារ SME Bank។ ទន្ទឹមនឹងនេះ ស្ថានីយចំនួន ៣ផ្សេងទៀត កំពុងសិក្សាកម្ចីពីធនាគារ SME Bank និងធនាគារ FTB។

ក្រៅពីនេះសមាគមក៏បានណែនាំប្រតិបត្តិករដែលមានតម្រូវការកម្ចីឱ្យទំនាក់ទំនងទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាដៃគូរបស់សមាគម និងអង្គការ Water.org ផងដែរ។

#### *ខ. កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍*

គម្រោងបានសម្របសម្រួលកិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ក្នុងគោលបំណងជំរុញឱ្យមានការគាំទ្រដល់អាជីវកម្មប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម៖

១. ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥ សមាគមបានជួបពិភាក្សាជាមួយ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ដើម្បីពិភាក្សាពីហិរញ្ញប្បទានសម្រាប់វិស័យទឹកស្អាត និងបង្កើនកិច្ចសហការជាមួយសមាគម។

២. ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបប្រជុំជាមួយតំណាងកម្មវិធី CAPRED ដើម្បីពិភាក្សាអំពីការរៀបចំហិរញ្ញប្បទានដែលមានឈ្មោះថា «Cambodian Climate Finance Facility» និងកិច្ចសហការនាពេលអនាគតសម្រាប់ការអនុវត្តហិរញ្ញប្បទាននេះ។ អ្នកចូលរួមសរុប ៤នាក់ (ស្រី ២នាក់) មកពីកម្មវិធី ២នាក់ និងសមាគម ២នាក់។ CAPRED បានបង្ហាញសង្ខេបអំពីផលិតហិរញ្ញប្បទាន និងប្រមូលព័ត៌មានសំខាន់ៗអំពីតម្រូវការរបស់ប្រតិបត្តិករលើប្រាក់កម្ចីនេះនាពេលអនាគត។

៣. ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបពិភាក្សាជាមួយសាជីវកម្មធានាឥណទានកម្ពុជា(CGCC) និងអង្គការ Water.org ដើម្បីពិភាក្សាលើលក្ខណៈនៃការធានាប្រាក់កម្ចី និងលក្ខខណ្ឌនៃអនុស្សរណៈនៃការយោគយល់គ្នា (MoU)។ ជាលទ្ធផលនៃកិច្ចប្រជុំ CGCC បានគូសបញ្ជាក់អំពីលក្ខណៈកម្ចីសំខាន់ៗដែលតម្រូវសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹក។ អ្នកចូលរួមសរុប ៧នាក់ (ស្រី ៣នាក់) មកពីអង្គការ Water.org ១នាក់ CGCC ៣នាក់ និងសមាគម ៣នាក់។




*រូបភាពទី២២៖ កិច្ចប្រជុំរវាង CWA, CGCC និងអង្គការ Water.org*

៤. នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៥ គម្រោងបានសម្របសម្រួលទស្សនកិច្ចសិក្សាសម្រាប់ក្រុមការងារ CGCC ដើម្បីជួបជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹក ខោ ប៊ុនហ៊ាត នៅខេត្តបាត់ដំបង ក្នុងការស្វែងយល់ពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

៥. នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបជាមួយ ធនាគារពិភពលោក និងក្រសួង ឧ.វ.ប.ន. ដើម្បីពិភាក្សាអំពីតួនាទីរបស់និយ័តករសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។ ក្នុងកិច្ចប្រជុំនោះ សមាគម បាន ស្នើសុំ ក្រសួងឧ.វ.ប.ន. និងធនាគារពិភពលោក ពិចារណាអំពីតួនាទីរបស់និយ័តករ គួររួមបញ្ចូល ១).ការពិនិត្យឡើងវិញនូវបទប្បញ្ញត្តិដែលមានស្រាប់ទាំងអស់ដើម្បីធានាថាបទប្បញ្ញត្តិទាំងអស់អាចប្រើប្រាស់និងមានប្រសិទ្ធភាពខ្ពស់ ២).ដោះស្រាយបញ្ហាសំខាន់ៗដែលប្រតិបត្តិករកំពុងប្រឈមដូចជា ការខូចខាតបណ្តាញបំពង់ទឹកស្អាតដែលបណ្តាលមកពីការសាងសង់ផ្លូវដោយគ្មានសំណង ការធានាប្រភពទឹកសម្រាប់ការផលិត និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព និងការផ្តល់នូវការគាំទ្រការកសាងសមត្ថភាពដល់ប្រតិបត្តិករ។

៦. នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបប្រជុំជាមួយ UK-Cambodia Strategic Infrastructure Chamber។ កិច្ចប្រជុំនេះ គឺដើម្បីផ្តល់ឱកាសឱ្យអ្នកជំនាញ និងហិរញ្ញប្បទានរបស់ចក្រភពអង់គ្លេសសម្រាប់កំណើនហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា ដោយភ្ជាប់ជាមួយក្រុមហ៊ុនឈានមុខគេរបស់ចក្រភពអង់គ្លេស និងការផ្តល់ហិរញ្ញប្បទានដើម្បីទទួលបានសេវាប្រឹក្សាយោបល់ ទំនិញ និងហិរញ្ញប្បទានលំដាប់ពិភពលោក ដើម្បីពន្លឿនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាពរបស់កម្ពុជា។ នេះរាប់បញ្ចូលទាំងសេវាធានាលើប្រាក់កម្ចីផងដែរ។

៧. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបប្រជុំជាមួយប្រធានទីផ្សារនៃក្រុមហ៊ុន LESSO Cambodia ដើម្បីពិភាក្សាអំពីការរៀបចំ កមវិធីទស្សនកិច្ចរោងចក្រផលិតបំពង់ទុយោ ក្រុមហ៊ុន LESSO Cambodia នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៥។ ក្នុងកម្មវិធីនេះដែរ ក្រុមហ៊ុនបានស្នើសុំឱ្យសមាគមសម្របសម្រួលអញ្ជើញប្រតិបត្តិករចំនួន៥០ស្ថានីយ។ ការស្នើនេះនឹងធ្វើការសម្រេចនៅក្នុងខែមេសា ឆ្នាំ២០២៥។

៨. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបប្រជុំជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការដ៏មានសក្តានុពលលើការទទួលបានហិរញ្ញប្បទានសម្រាប់វិស័យទឹក។ ក្នុងកិច្ចប្រជុំ សមាគមបានស្នើឱ្យអម្រឹតចូលជាសមាជិកគាំទ្ររបស់សមាគម និងរៀបចំអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីផ្តល់លក្ខខណ្ឌហិរញ្ញប្បទានពិសេសដល់ប្រតិបត្តិករដែលជាសមាជិកសមាគម។

៩. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ សមាគមបានជួបប្រជុំជាមួយធនាគារ Phillip Bank Plc. ដើម្បីពិភាក្សាអំពីការរៀបចំអាហារពេលល្ងាចសាមគ្គីសម្រាប់សមាជិកចំនួន ២០០នាក់ និងស្វែងយល់ពីកិច្ចសហការដ៏មានសក្តានុពលរវាងធនាគារ Phillip Bank Plc. និងសមាគម។ ជាលទ្ធផលនៃកិច្ចប្រជុំ ធនាគារ Phillip Bank Plc. បានបង្ហាញចំណាប់អារម្មណ៍ក្នុងការក្លាយជាសមាជិកសមាគម។ ធនាគារ Phillip Bank Plc. ក៏បានស្នើសុំជំនួយពីសមាគមក្នុងការរៀបចំអាហារពេលល្ងាចសាមគ្គីសម្រាប់សមាជិកចំនួន១០០នាក់ និងបានបង្ហាញចំណាប់អារម្មណ៍ក្នុងការបង្កើតអនុស្សរណៈយោគយល់គ្នា (MoU) ជាមួយសមាគម ដើម្បីផ្តល់លក្ខខណ្ឌហិរញ្ញប្បទានពិសេសដល់ប្រតិបត្តិករដែលជាសមាជិកសមាគម។

*គ. កសាងសមត្ថភាព និងចំណេះដឹងលើវិស័យហិរញ្ញប្បទាន*

១. នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥ លោកស្រី ស៊ឹម បូនិច និងលោកស្រី តូច សុគន្ធា បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី«ការវិភាគហិរញ្ញវត្ថុរបស់ប្រតិបត្តិករទឹកឯកជនសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ» ដែលផ្តល់ឧបត្ថម្ភមូលនិធិដោយអង្គការ Water.org និងសម្របសម្រួលដោយក្រុមហ៊ុនបញ្ញី។

### ៥.១.៤ ការគាំទ្រលើផែនការអាជីវកម្មជូនសមាជិកគម្រោង

គម្រោងបានសម្របសម្រួលកិច្ចប្រជុំរវាងប្រតិបត្តិករ ក្រុមហ៊ុន iSEA និងអង្គការ Water.org ដើម្បីពិនិត្យ និងបញ្ចប់លើផែនការអាជីវកម្ម និងគូរផែនទីបណ្តាញ ជូនប្រតិបត្តិករចំនួន៦។ ជាលទ្ធផល ប្រតិបត្តិករទាំង៦ ទទួលបានផែនទីបណ្តាញ និងប្រតិបត្តិករ ៥ក្នុងចំណោម៦ ទទួលបានផែនការអាជីវកម្ម Business Plan។

### ៥.១.៥ កិច្ចប្រជុំក្នុងគម្រោង

នៅក្នុងត្រីមាសទី១ ក្រុមការងាររបស់គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រុមការងារគម្រោងបានជួបប្រជុំរវាងអង្គការ Water.org និងសមាគម ដើម្បីពិភាក្សាអំពីគម្រោងថ្មី និងលម្អិតអំពីសកម្មភាពគន្លឹះមួយចំនួន។ អ្នកចូលរួមសរុបចំនួន ៦នាក់ (ស្រី ៣នាក់)។

២. ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ក្រុមការងារគម្រោង (CWA & Water.org) បានជួបប្រជុំដើម្បីពិនិត្យមើលលើវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ និងលើកផែនការសម្រាប់ត្រីមាសទី២ ព្រមទាំងជួបប្រជុំជាមួយឯកឧត្តម **គន់ សុខជា** អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧ.វ.ប.ន. ដើម្បីសុំយោបល់ និងអនុសាសន៍ក្នុងការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងបទប្បញ្ញាតទឹកស្អាតផងដែរ។